# សន្និសីទមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០០៧: ជំហានថ្មីឆ្ពោះទៅមុខ

## សមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា

## ការអភិវឌ្ឍន៍ផលិតផលថ្មី នៃមីក្រូហិរញ្ញវត្ថុ

## ក្នុងបរិបទ កម្ពុជា

បណ្ឌិត ប៊ុន មុនី

ភ្នំពេញ ២៩ វិច្ឆិកា ២០០៧

# I.សាវតារ

- ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលបឋម ក្នុងការអភិវឌ្ឍន៍
- ប្រព័ន្ធហិរញ្ញវត្ថុនេះ បានចាប់ផ្តើមនាទសវត្សទី ៩0 ក្រោយពីកំណែទំរង់សេដ្ឋកិច្ច ទៅជាសេដ្ឋកិច្ចទីផ្សារសេរី
- កត្តាដែលឈានមុខគេបំផុតនៃវិស័យហិរញ្ញវត្ថុ នៅកម្ពុជានេះ គឺ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលសកម្មភាពទាំងឡាយរបស់ប្រតិបត្តិករគឺស្ថិតនៅក្រោម ការគ្រប់គ្រងនៃច្បាប់ដ៏ខ្ជាប់ខ្ជួន និងហ្មឹងម៉ាត់
- វិស័យនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់ថ្មីមួយ ស្តីអំពីធនាគារ និង ហិរញ្ញវត្ថុដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៩។ ស្ថានភាពធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជាបច្ចុប្បន្ន រួមមាន :
    - ធនាគារពាណិជ្ជ ចំនួន ១៧
    - ធនាគារឯកទេស ចំនួន ៦
    - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានអាជ្ញាប័ណ្ណ ចំនួន ១៧
    - ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ចុះបញ្ជី ចំនួន ២៥

## II.ផលិតផល_សេវាកម្ម របស់ មីក្រូហិរញ្ញវត្ថុ

- **ក_ ឥណទាន**

១- ឥណទានខ្នាតតូចបំផុត មានទំហំជាមធ្យម ៥0 ដុល្លា-៥00 ដុល្លាអាមេរិក

២- ឥណទានខ្នាតតូច មានទំហំជាមធ្យម ៥00 ដុល្លា-៥000 ដុល្លាអាមេរិក

៣- ឥណទានខ្នាតមធ្យម មានទំហំជាមធ្យម ៥.000 ដុល្លា-១0.000 ដុល្លាអាមេរិក

៤- ឥណទានបុគ្គលិក អាស្រ័យតាមគោលការរបស់គ្រឹះស្ថាននិមួយៗ

- **ខ_វិធីសាស្ត្រនៃការផ្តល់ ឥណទាន**

១. ធនាគារភូមិ ឬធនាគារសហគមន៍ មានសមាជិកជាមធ្យម ១៥-១00 នាក់អាស្រ័យតាមគោលការរបស់គ្រឹះស្ថាន

២. ក្រុមសាមគ្គី ឬ ជាក្រុមធានាគ្នា មានសមាជិកជាមធ្យម ៣-១0 នាក់អាស្រ័យតាមគោលការរបស់គ្រឹះស្ថាននិមួយៗ

៣. ប្រភេទជាឯកត្តជន ( ម្នាក់ៗ) កំពុងពេញនិយមចំពោះប្រភេទ ឥណទានខ្នាតតូច និង មធ្យម និងមានទ្រព្យធានា

# II.ផលិតផល សេវាកម្ម របស់ មីក្រូហិរញ្ញវត្ថុ (ត)

- **ខ_វិធីសាស្ត្រនៃការផ្តល់ ឥណទាន (ត)**

៤- ធនាគារចល័ត គឺជាការផ្តល់សេវាកម្មដល់លំនៅដ្ឋានប្រជាពលរដ្ឋ តាមរយៈភ្នាក់ងាររបស់គ្រឹះស្ថាន

៥-សេវាកម្មនៅការិយាល័យ តាមរយៈការបង្កើតការិយាល័យជិតលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ពោលគឺទិស
ដៅឆ្ពោះទៅកាន់ទីជនបទដែលមានការិយាល័យតាមទីរួមខេត្ត-ស្រុក និង ឃុំ ។

- **គ_រូបិយប័ណ្ណចរាចរក្នុងការ ផ្តល់ឥណទាន**

១- ឥណទានជាប្រាក់រៀល

១- ឥណទានជាប្រាក់ដុល្លាអាមេរិក

១- ឥណទានជាប្រាក់បាតថៃ

# II.ផលិតផលសេវាកម្ម របស់ មីក្រូហិរញ្ញវត្ថុ (ត)

- **រយៈពេលឥណទាន របៀបសងត្រឡប់វិញ អត្រាការប្រាក់ និង ការគណនា**

១- រយៈពេលឥណទានជាមធ្យមមានចាប់ពី ៦ខែ រហូតដល់ ២៤ ខែ

២-របៀបសងត្រឡប់វិញមានច្រើនជំរើសដូចជា:

- ការសងប្រាក់ដើម និងការប្រាក់នៅចុងវគ្គ ឬបង់សងការប្រាក់ប្រចាំខែ និង សងប្រាក់ដើមនៅចុងវគ្គ
- អនុញ្ញាតឱ្យមានការសំរាកបង់សងនៅដើមគ្រាមួយរយៈ និងចាប់ផ្ដើមសងប្រាក់ដើម និង ប្រាក់ការ ចាប់ពីពាក់កណ្ដាលទុនឡើងទៅដោយរំលស់ប្រចាំខែ (ឬជំរើសផ្សេងដែលស្រដៀងគ្នានេះ)។
- ការបង់សងរំលស់ប្រចាំខែរួមមានប្រាក់ដើម និង ការប្រាក់

៣-អត្រាការប្រាក់ស្ថិតក្នុងចន្លោះ ២%-៣% ក្នុង ១ ខែ

៤- ការគណនាការប្រាក់គឺអនុវត្តតាមអត្រារំលស់ ដោយគណនាការប្រាក់លើតែសមតុល្យឥណទាន

ដែលនៅសល់តែប៉ុណ្ណោះ

# III.ផលិតផលថ្មីកំពុងសាកល្បងសេវាប្រាក់បញ្ញើ និងផ្ទេរប្រាក់អន្តរសាខា

- ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសាកល្បងកេណ្ឌប្រមូលប្រាក់សន្សំសាធារណៈពីក្នុងតំបន់ដែលខ្លួនកំពុងប្រតិបត្តិការ ។ សេវាកម្មសន្សំប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបច្ចុប្បន្នរួមមានៈ

**១-បញ្ញើភាគព្វកិច្ច**

គ្រឹះស្ថានមួយចំនួនបានតំរូវឱ្យអតិថិជនរបស់ខ្លួនដាក់ប្រាក់បញ្ញើតូចៗ នៅពេលដែលគេខ្ចីប្រាក់ ។ គម្មវិធីនេះគឺធ្វើឡើងក្នុងគោលបំណងបង្រៀនអតិថិជនឱ្យស្គាល់ពីសេវាកម្មសន្សំប្រាក់ និង អត្ថប្រយោជន៏របស់វា។

**២- សេវាបញ្ញើសន្សំស្ម័គ្រចិត្ត**

គ្រឹះស្ថានមួយចំនួនបានផ្តល់សេវាកម្មសន្សំស្ម័គ្រចិត្តនេះក្នុងការសាកល្បងកេណ្ឌប្រមូលប្រភពទុនដើម្បីប្រើប្រាស់ជាទុនបង្វិលដែលជាប្រភពទុនមានតំលៃថោក និង មាននិរន្តភាពក្នុងការអភិវឌ្ឍន៏មីក្រូហិរញ្ញវត្ថុក្នុងរយៈពេល វែង។ ផលិតផលសន្សំស្ម័គ្រចិត្តបច្ចុប្បន្នមាន :

ក- សេវាសន្សំប្រាក់ដោយប្រើសៀវភៅ (Passbook Saving)

ខ- សន្សំមានកាលកំណត់ (Term Deposit)

# III.ផលិតផលថ្មីកំពុងសាកល្បងសេវាប្រាក់បញ្ញើ និងផ្ទេរប្រាក់អន្តរសាខា (ត)

**៣- ការផ្ទេរប្រាក់អន្តរសាខា :** គ្រឹះស្ថានមួយចំនួនបានផ្តល់សេវាកម្ម ផ្ទេរប្រាក់ ឬ ការទូទាត់ ឬ ការផ្ញើរប្រាក់ជាអន្តរសាខា នៅក្នុងដែនប្រតិបត្តិការរបស់ខ្លួន ។ សេវាកម្មនេះបានគាំទ្រដល់កម្មវិធីកេណ្ឌប្រមូលប្រាក់សន្សំសាធារណៈ ។

**៤- សេវាកម្មផ្សេងទៀត :**

ក- សេវាកម្មឥណទាន ប្រាក់បញ្ញើតាមរយៈទូរស័ព្ទដៃ ដែលអនុញ្ញាតិឱ្យអតិថិជនធ្វើការទូទាត់ ដាក់បញ្ញើ ឬ ទទួលឥណទានតាមរយៈទូរស័ព្ទដៃ ។ ផលិតផលនេះកំពុងមាននិយមនៅក្នុងប្រទេសមួយចំនួន ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាមិនទាន់ចាប់ផ្តើមនៅឡើយ ។

ខ- ការធានារ៉ាប់រងខ្នាតតូចៈ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានសាកល្បងផ្តល់សេវាកម្មធានារ៉ាប់រងខ្នាតតូចដែលសកម្មភាពនេះនឹងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# IV. ឥទ្ធិពលរបស់មីក្រូហិរញ្ញវត្ថុ

- រហូតដល់ដំណាច់ខែកញ្ញា ឆ្នាំ ២០០៧ នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៧ និង ធនាគារពាណិជ្ជមួយ ( អតីតមីក្រូហិរញ្ញវត្ថុ) បានផ្តល់សេវាកម្មដល់សហគ្រិនខ្នាតតូច និង តូចបំផុតបានចំនួន ៧៤០.២៤៩ គ្រួសារដែលស្មើ នឹង ២៩% នៃគ្រួសារនៅកម្ពុជាសរុប ។ សរុបឥណទានដែលមាននៅដៃអតិថិជនចំនួន ២៤០ លានដុល្លារ អាមេរិក ។ សេវាកម្មមីក្រូហិរញ្ញវត្ថុបានពង្រីកទៅដល់ខេត្តក្រុង ទាំង២៤ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មានការិយាល័យប្រតិបត្តិការចំនួន **៤៥៨** ដែលកំពុងបំរើអតិថិជនដល់ទីជនបទ ។

- អតិថិជនច្រើនជាង ៩០% បានបង្កើនប្រាក់ចំណូលរបស់ពួកគេតាមរយៈប្រភពទុនកំចីនេះ និងឈានទៅលើកកម្ពស់ជីវភាពរស់នៅឱ្យកាន់តែមានភាពប្រសើរឡើង ព្រមទាំងអាចពង្រីកអាជីវកម្មរបស់ពួកគេ និងទទួលបានជោគជ័យជាបន្តបន្ទាប់ ។ ពលរដ្ឋក្រីក្រកម្ពុជាភាគច្រើនបំផុត បានចាត់ទុកមីក្រូហិរញ្ញវត្ថុជាដៃគូមិនអាចខ្វះបាន នៅក្នុងតួនាទីអភិវឌ្ឍន៏សេដ្ឋកិច្ច របស់ពួកគេ ។ លើសពីនេះទៅទៀត មីក្រូហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ ថាជាបច្ចេកវិជ្ជាថ្មីសំរាប់កម្ពុជាដែលជា " **កូនសោចាក់នំលាយ ចេញពីភាពក្រីក្រ** " សំរាប់ប្រទេសនេះ និង ប្រទេសក្រីក្រនានា ។

# V. កត្តាប្រឈមរបស់មីក្រូហិរញ្ញវត្ថុ

- សេវាកម្មមីក្រូហិរញ្ញវត្ថុបានទទួលជោគជ័យធំធេង នៅលើសេវាកម្មតែមួយផ្នែកប៉ុណ្ណោះ គឺប្រាក់កំចី ។ ដោយឡែកសេវាកម្មសំខាន់មួយទៀតរបស់មីក្រូហិរញ្ញវត្ថុ គឺ សេវាប្រាក់បញ្ញើដែលជាការកេណ្ឌប្រមូលប្រភពទុន យកមកផ្គត់ផ្គង់សេវាប្រាក់កំចីនេះ នៅមិនទាន់បានទទួលការគាំទ្រពីសាធារណៈជនបានទូលំទូលាយទេ ។ ដូច្នេះហើយប្រតិបត្តិករភាគច្រើន ត្រូវស្វែងរកកំចីទុនពីបរទេសយកមកប្រើប្រាស់ ដែលទុននេះមានតំលៃថ្លៃ រួមទាំងការបង់ពន្ធកាត់ទុក ១៤% លើការប្រាក់ ធ្វើឱ្យឥណទាននេះរឹតតែថ្លៃ និងការផ្តល់ឥណទានបន្តដល់អ្នកប្រើប្រាស់ មានតំលៃខ្ពស់ដែរ ទោះជាមានការកាត់បន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់ហើយក៏ដោយ ។
- ការកេណ្ឌប្រមូលប្រាក់សន្សំសាធារណៈដែលជាប្រភពទុនមិនចេះរីងស្ងួត សំរាប់ផ្គត់ផ្គង់ទុនដល់មីក្រូហិរញ្ញវត្ថុ និងមានតំលៃទាបសមរម្យដែលអាចឈានទៅបញ្ចុះការប្រាក់ដល់អ្នកប្រើប្រាស់ ដែលគាំទ្រការអភិវឌ្ឍន៍មុខរបររបស់ពួកគេ ។ ប៉ុន្តែជាអកុសល គ្រឹះស្ថានហិរញ្ញវត្ថុមិនទាន់មានជោគជ័យលើសេវាកម្មប្រាក់បញ្ញើនេះនៅឡើយទេ ដែលទាមទារអោយមានការប្រឹងប្រែងបន្ថែមទៀតរបស់ប្រតិបត្តិករ និង ភាគីពាក់ព័ន្ធទាំងឡាយ ។
- ផលិតផល សេវាកម្ម របស់មីក្រូហិរញ្ញវត្ថុរួមមាន សេវាកម្មប្រាក់កំចី និង សេវាកម្មប្រាក់បញ្ញើ ដែលផលិតផលទាំងពីរនេះត្រូវមានដំណើរទន្ទឹមគ្នា ដើម្បីគាំទ្រគ្នាទៅវិញទៅមក ពោលគឺសេវាកម្មប្រាក់បញ្ញើត្រូវកេណ្ឌប្រមូលប្រាក់បញ្ញើពីសាធារណៈជន និង ផ្គត់ផ្គង់ជាប្រភពទុនផ្តល់ឱ្យអតិថិជនដែលត្រូវការវិនិយោគក្នុងអាជីវកម្មរបស់គេ ។

# V. កត្តាប្រឈមរបស់មីក្រូហិរញ្ញវត្ថុ (ត)

- ការលំបាករបស់មីក្រូហិរញ្ញវត្ថុក្នុងការកេណ្ឌប្រមូលប្រាក់បញ្ញើ ទាក់ទងទៅនឹងកត្តាធំ ២ គឺ : ១). ប្រព័ន្ធច្បាប់ មិនទាន់  មានការគាំទ្រពេញលេញនៅឡើយ។ ២). ប្រជាជនកម្ពុជា មិនមាន ទំលាប់ប្រើប្រាស់សេវាកម្មធនាគារ ឬ មីក្រូហិរញ្ញវត្ថុ (ដែលរួមមានប្រាក់កំចី និង ប្រាក់បញ្ញើ) នៅក្នុង ជីវភាពប្រចាំ ថ្ងៃ។
- ធនាគារជាតិដែលជាអាជ្ញាធរមានសមត្ថកិច្ចគួរតែផ្តល់សិទ្ធិពេញលេញ ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការកេណ្ឌ ប្រមូលសន្សំសាធារណៈដែលជាការបន្ថែមទំងន់នៃការទុកចិត្តរបស់សាធារណៈជនចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- សេវាកម្មធនាគារ ឬ មីក្រូហិរញ្ញវត្ថុរួមមាន ប្រាក់កំចី និង បញ្ញើនេះគឺមានគុណសម្បត្តិច្រើនសំរាប់អ្នកប្រើប្រាស់ និង សំរាប់សេដ្ឋកិច្ចជាតិដោយ អ្នកសន្សំប្រាក់ទទួលបានការថែទាំ មូលនិធិរបស់ពួកគេបានល្អគង់វង់ និង មានការប្រាក់ បន្ថែម និង មូលនិធិនេះត្រូវបានយកទៅផ្តល់ជាកំចី ប្រើប្រាស់ដើម្បីផលប្រយោជន៏សេដ្ឋកិច្ច ដែលជាការរួមចំណែក ធ្វើឱ្យមាន ស្ថេរភាពសាច់ប្រាក់ និង ស្ថេរភាពសេដ្ឋកិច្ច។ សម័យមុន ការបើកគណនីនៅធនាគារមានលក្ខណៈលំបាក ដោយធនាគារភាគច្រើនបោះទីតាំងនៅទីប្រជុំជនដែលឆ្ងាយក្នុងការធ្វើដំណើរ ត្រូវចំណាយពេលវេលា និង ថវិកា ដើម្បីទទួលសេវាកម្មនេះ ព្រមទាំងការបើកគណនីនីមួយៗត្រូវបង់កំរៃថែមទៀត។ បច្ចុប្បន្ននេះ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុបានបោះទីតាំងខិតមកជិត លំនៅដ្ឋានលោកអ្នក រួមទាំងការបើកគណនី មិនទាមទារបង់កំរៃអ្វីឡើយ។

# V. កត្តាប្រឈមរបស់មីក្រូហិរញ្ញវត្ថុ (ត)

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា គឺស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងរបស់អាជ្ញាធរដែលបញ្ជាក់ពីភាពត្រឹមត្រូវនូវគ្រប់សកម្មភាពរបស់ប្រតិបត្តិករនីមួយៗដូចជា ធនាគារពាណិជ្ជក្នុងការធានាសុវត្ថិភាព និង ផលប្រយោជន៍របស់សាធារណៈជន។ ដូច្នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណជាកន្លែងដែលមានសុវត្ថិភាពក្នុងការដាក់ប្រាក់បញ្ញើដូចធនាគារពាណិជ្ជដែរ។ ប្រជាពលរដ្ឋកម្ពុជាគួរតែបាន ប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុ រួមមានប្រាក់កំចី និងបញ្ញើនេះនៅក្នុងជីវភាពប្រចាំថ្ងៃ ដូចប្រជាពលរដ្ឋនៅក្នុងប្រទេស រីកចំរើននានាដែរ។
- ដើម្បីនិរន្តភាព គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិតជាត្រូវការការគាំទ្រ ពីគ្រប់ភាគីពាក់ព័ន្ធដែលរួមមាន ពីសំណាក់រាជរដ្ឋាភិបាល អ្នកវិនិយោគទុន ប្រតិបត្តិករ និង សាធារណៈជន។ វិភាគទានរបស់លោកអ្នក ជាមួយមីក្រូហិរញ្ញវត្ថុ គឺជាការរួមចំណែកកសាង និង អភិវឌ្ឍន៍ជាតិ យ៉ាងពិតប្រាកដ។

# សូមអរគុណ